# ស្តង់ដាសាលារៀនគំរូ

ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

ស្តង់ដាទី២៖ ការបង្រៀននិងរៀន

ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន

ស្តង់ដាទី៥ ៖ គណនេយ្យភាពរបស់សាលារៀន

# ស្តូចដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

សូចនាករសំខាន់ៗ ៖

- **១. ការប្រមូលកុមារចូលរៀន៖** ភាគរយកុមារអាយុ ៣ឆ្នាំ, ៤ឆ្នាំ, ៥ឆ្នាំ បានចូលរៀន, អត្រាពិតនៃការសិក្សានៅបឋមសិក្សា, ភាគរយកុមារចូលរៀនត្រូវតាមអាយុ
- **២. កុមាររៀនបានគង់វង្សក្នុងសាលារៀន៖** អត្រាត្រួតថ្នាក់ថយចុះ, អត្រាបោះបង់ការសិក្សាថយចុះ
- **៣. លទ្ធផលនៃការសិក្សារបស់សិស្ស៖** ភាគរយកុមារអាយុ ៣ឆ្នាំ, ៤ឆ្នាំ, ៥ឆ្នាំ មានការអភិវឌ្ឍផ្នែកទាំង ៥, ភាគរយសិស្សសម្រេចបាននិទ្ទេស A, B, C លើមុខវិជ្ជា ភាសាខ្មែរ, គណិតវិទ្យា និងស្ទែម , ភាគរយសិស្សថ្នាក់ទី៣មានសមត្ថភាពអានតាមស្តង់ដា (៤៥ទៅ៦០ពាក្យក្នុងមួយនាទី), ភាគរយសិស្សថ្នាក់ទី៦មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី), ភាគរយសិស្សជាប់តេស្តស្តង់ដាថ្នាក់ទី៣និងទី៦, ភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី), ភាគរយសិស្សថ្នាក់ទី៩ មានសមត្ថភាពអានតាមស្តង់ដា (២០០ទៅ២៥០ពាក្យក្នុងមួយនាទី), ភាគរយសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬមធ្យមសិក្សាទុតិយភូមិ។

## ស្តង់ដារទី១៖ លទ្ធផលសិក្សារបស់សិស្ស

សូចនាករសំខាន់ៗ ៖

- **៤. ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស៖** ភាគរយកុមារមានស្ថានភាពអាហារូបត្ថម្ភប្រសើរឡើង, សាលារៀនបានរៀបចំកម្មវិធីអាហារពេលព្រឹក ឬ អាហារសម្រន់សម្រាប់កុមារប្រកបដោយ គុណភាព, ភាគរយសិស្សក្រីក្រទទួលបានអាហារូបករណ៍ ឬការឧបត្ថម្ភនានា
- **៥. សីលធម៌ និងឥរិយាបថរបស់សិស្ស៖** ចំនួនកុមារទទួលរងអំពើហិង្សាបានថយចុះ, ការបញ្ចូលពិន្ទុ សីលធម៌និងឥរិយាបថសិស្សទៅក្នុងពិន្ទុរួម, ចំនួននិងភាគរយសិស្សទទួលបានមូលវិចារណ៍ល្អលើ ផ្នែកវិន័យ សីលធម៌ និងឥរិយាបថ។

# ស្តង់ដាទី២៖ ការបង្រៀន និងរៀន

សូចនាករសំខាន់ៗ ៖

- **១. ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី៖** សាលារៀនបានអនុវត្តវិធីសាស្ត្ររៀនតាមរយៈការលេង (Learning through Play), ភាគរយគ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ អនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង គណិតវិទ្យាដំបូងកម្រិតទី៣, ភាគរយសិស្សបានធ្វើកិច្ចការជាគម្រោង
- **២. ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន៖** សាលារៀនមានរៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែតាមមុខវិជ្ជា និងរៀបចំផែនការបង្រៀនប្រចាំថ្ងៃ, ចំនួនគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ, គ្រូបង្រៀនបានធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀនត្រឹមត្រូវ និងបានអនុវត្តទៀងទាត់, សាលារៀនបានប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ, ភាគរយថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា, ភាគរយគ្រូអវត្តមាន, ភាគរយសិស្សអវត្តមាន, ចំនួនថ្ងៃសាលារៀនបិទទ្វារ

# ស្តង់ដារទី២៖ ការបង្រៀន និងរៀន

សូចនាករសំខាន់ៗ ៖

- **៣. សម្ភារៈរៀននិងបង្រៀន៖** ផលធៀបសិស្ស-សៀវភៅសិក្សាគោល, ភាគរយសិស្សមានសៀវភៅសិក្សាគោលមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម, ភាគរយនៃការបើកដំណើរការបន្ទប់កុំព្យូទ័រតាមផែនការ, ភាគរយនៃការបើកដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំង៤តាមផែនការ, ដំណើរការ គាំទ្រ និងអភិវឌ្ឍបន្ទប់ពហុបំណង
- **៤. ការជួយគាំទ្រសិស្ស៖** ភាគរយសិស្សបានធ្វើកិច្ចការផ្ទះនិងមានការកែពីគ្រូ, ចំនួននិងភាគរយថ្នាក់រៀនមានក្លឹបស្វ័យសិក្សាមានដំណើរការ
- **៥. ដំណើរការបណ្ណាល័យ៖** សាលារៀនបានរៀបចំបណ្ណាល័យត្រឹមត្រូវ និងបានដំណើរការជាប្រចាំ,
- **៦. ការធ្វើអធិការកិច្ចផ្ទៃក្នុង៖** នាយកសាលារៀនបានចុះធ្វើអធិការកិច្ចផ្ទៃក្នុងតាមផែនការ, ភាគរយគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ/អធិការកិច្ចផ្ទៃក្នុងយ៉ាងតិចម្តងក្នុង១ឆ្នាំ

# ស្តង់ដាទី២៖ ការបង្រៀន និងរៀន

- **៧. ការប្រជុំបច្ចេកទេស៖** គ្រូបង្រៀនបានប្រជុំបច្ចេកទេសទៀងទាត់តាមផែនការរបស់សាលារៀន
- **៨. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្អាត៖** សាលារៀនមានសួនកុមារនិងសម្ភារៈសម្រាប់កុមារលេងដោយ សេរីនិងមានសុវត្ថិភាព, សាលារៀនទទួលបានពិន្ទុតាមរយៈឧបករណ៍វាយតម្លៃសាលារៀនស្អាត, សាលារៀននិងថ្នាក់រៀនមានផែនការសកម្មភាពកែលម្អបរិស្ថានថ្នាក់រៀន សាលារៀន និងភូមិ ផ្តោតលើការដាំដើមឈើ និងរៀបចំសួនបន្លែសម្រាប់គ្រួសារ
- **៩. ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា៖** ភាគរយថ្នាក់ទី៤-៦ មានបង្រៀនភាសាបរទេស, ចំនួនដងសិស្សថ្នាក់ទី៤-៦រៀនកុំព្យូទ័រ, ភាគរយសិស្សថ្នាក់ទី៤-៦ រៀនសូត្របំណិនជីវិតមូលដ្ឋាន, ភាគរយសិស្សបានសន្សំប្រាក់ដើម្បីបន្តការសិក្សានៅមធ្យមសិក្សា, ចំនួននិងភាគរយសិស្សរៀនសូត្របំណិន កសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល, ចំនួននិងភាគរយសិស្សបានសន្សំប្រាក់ និងសម្រេចចិត្តទៅរៀននៅឧត្តមសិក្សាតាមបំណងប្រាថ្នា

# ស្តង់ដារទី២៖ ការបង្រៀន និងរៀន

– ១០. ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌៖

- *សាលារៀនបានអនុវត្តកម្មវិធីលើកកម្ពស់ចរិយាធម៌ (ស្អាត សុភាព របៀប ទៀងពេល និង សមាធិ)*
- *សាលារៀនមានសកម្មភាពកីឡា (មានតារាងនិងសិស្សលេងបាល់ទះ មានតារាងនិងសិស្សលេងបាល់ទាត់ មានតារាងនិងសិស្សលេងបាល់បោះ មានតារាងនិងសិស្សលេងវាយសី...)*
- *សាលារៀនមានសកម្មភាពអប់រំសិល្បៈ (ចម្រៀង គំនូរ របាំ តន្ត្រី)*
- *សាលារៀនបានអនុវត្តកម្មវិធីអភិវឌ្ឍយុវជន៖ ដំណើរការរបស់ក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន,*
- *កម្មវិធីមិត្តអប់រំមិត្ត និងកម្មវិធី ៣ល្អ, កម្មវិធីប្រកួតប្រជែងវោហាស័ព្ទ និងជជែកដេញដោល, កម្មវិធីសិល្បៈ និងកីឡា, កម្មវិធីស្ម័គ្រចិត្តក្នុងសហគមន៍, កម្មវិធីបរិស្ថាន និងការសម្អាតសាលារៀន, កម្មវិធីបោះជំរំ, ក្លឹបសិក្សា ស្វ័យសិក្សា និងកម្មវិធីជួយសិស្សរៀនយឺត, កម្មវិធីសប្បុរសធម៌ ។ល។*

# ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

សូចនាករសំខាន់ៗ ៖

- **១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖** ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស.), ភាគរយថ្នាក់រៀនបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ.), ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយ គ.គ.ស., ភាគរយគ្រូបង្រៀនបានទទួលការសម្រេចចិត្តពី គ.គ.ស. លើការវាយតម្លៃ ការអនុវត្តការងារប្រចាំឆ្នាំ, ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពី គ.គ.ស. លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ
- **២. ការចូលរួមរបស់សហគមន៍៖** ព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និងបិទផ្សាយជាសាធារណៈ, សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ, សហគមន៍ចូលរួមរៀបចំបរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារិម និងបរិក្ខារសិក្សា, សាលារៀនមានកិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ, មាតាបិតាឬអ្នកអាណាព្យាបាលចូលរួម អនុវត្តកម្មវិធីអប់រំទៀងទាត់
- ៣. ការគាំទ្ររបស់សហគមន៍៖ បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន, សហគមន៍បានធ្វើសកម្មភាពជួយកុមារនៅតាមផ្ទះ, ចំនួននិងភាគរយគ្រួសារទទួលរងអំពើហឹង្សាថយចុះ។

# ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

- ៤. **វាយតម្លៃលទ្ធផលសិក្សា៖** សាលារៀនបានរៀបចំការវាយតម្លៃលទ្ធផលសិក្សាកុមារតាមកម្មវិធីសិក្សា, ការធ្វើតេស្តស្តង់ដាដើមឆ្នាំ ប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់, ចំនួនខែដែលបានជួយសិស្សរៀនយឺតផ្អែកតាមលទ្ធផលតេស្តស្តង់ដាប្រចាំខែ
- ៥. **ការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់សិស្ស៖** សាលារៀនមានបរិក្ខារទឹកស្អាត, អនាម័យ និងបន្ទប់ទឹក, សាលារៀនមានផ្តល់អាហារពេលព្រឹក, អាហារូបករណ៍
- ៦. **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ៖** សាលារៀនមានបណ្តាញអគ្គិសនី បំពាក់អ៊ីនធើណេតបន្ទប់កុំព្យូទ័រ បណ្ណាល័យ, ភាគរយ បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Board...)។

# ស្តង់ដារទី៥៖ គណនេយ្យភាពរបស់សាលារៀន

សូចនាករសំខាន់ៗ ៖

- **១. វេទិកាសាធារណៈ៖** ការជួបប្រជុំមាតាបិតាសិស្ស (ទៅតាមប្រធានបទដូចជា ការណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់អំពីហិង្សានៅក្នុងគ្រួសារនិងសាលារៀន, ការជំរុញការសិក្សារៀនសូត្រ, ការលើកកម្ពស់អាហារូបត្ថម្ភ, ការអប់រំអំពីគ្រឿងញៀន ច្បាប់ចរាចរ និង ការងារផ្សេងៗទៀត)
- **២. ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ៖** ការបង្ហាញលទ្ធផលសិក្សា, សាលារៀនបានផ្សព្វផ្សាយ សកម្មភាពប្រតិបត្តិនិងសមិទ្ធផលជាសាធារណៈ, ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ
- **៣. ការទទួលបានការគាំទ្រពីថ្នាក់ជាតិ៖** ចំនួនជងនាយកសាលានិងនាយករង បានទទួលការហ្វឹកហាត់ អនុវត្តការគ្រប់គ្រងតាមសាលារៀន, ភាគរយគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង និង/ឬវិធីសាស្ត្របង្រៀនភាសាខ្មែរ និងគណិតវិទ្យា, ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រតាមផែនការ, នាយកសាលានិងនាយករងបានទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ, សាលារៀនទទួលការចុះជួយបច្ចេកទេសពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរ។